របាយការណ៍វាយតម្លៃលទ្ធភាពសង

លេខ: ០០៤/២៣

ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

# ស៊ីអាយអេ ហ្វីស អ៊ិនធើណេសិនណល ស្កូល

| ចំណាត់ថ្នាក់ឥណទាន | | ព័ត៌មានសញ្ញាបណ្ណ | |
|---|---|---|---|
| ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន | khBB | ទំហំ | ១០ លានដុល្លារអាមេរិក |
| ការវាយតម្លៃ | **អវិជ្ជមាន** | ចំនួននៃការទូទាត់ | ប្រចាំឆមាសសម្រាប់ការទូទាត់ការប្រាក់ និងប្រចាំឆ្នាំសម្រាប់ការទូទាត់ប្រាក់ដើម |
| ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ | khAAA | រយៈពេលឥណប្រតិទាន | ៥ឆ្នាំ(មិនមានការទូទាត់ប្រាក់ដើមរយៈពេល១ឆ្នាំ) |
| | | ប្រភេទ | មិនមានទ្រព្យតម្កល់ ប៉ុន្តែមានបុគ្គលធានា |
| | | អត្រាគូប៉ុង | ៦.៣% ក្នុងមួយឆ្នាំ |
| | | បុគ្គលធានា | Credit Guarantee & Investment Facility (CGIF) |

**អ្នកវាយតម្លៃ៖**

លោក ស៊ីសុវត្ថិ ចក្រការា CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

កញ្ញា សៀង ដារីយ៉ា
s.darya@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៨៦ ៧៧៧

កញ្ញា ពៅ ស៊ុនវណ្ណដែត
p.sunvandeth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣១៨ ៧៧៧

កញ្ញា លឹម អច្ឆរាទេពី
l.achhakratepy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

អ្នកស្រី សុង ហេងជូលី
hengjulie.song@3e-fii.com
(+៨៥៥) ៨៩ ២៣៩ ២៤៩

លោក ញាន តុលា
tola.nhean@3e-fii.com

## ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

ការវាយតម្លៃបច្ចុប្បន្នគឺផ្អែកលើចរិតលក្ខណៈនៃសញ្ញាបណ្ណដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះ និងនៅលើកិច្ចព្រមព្រៀងធានា និងឯកសារពាក់ព័ន្ធផ្សេងទៀតទាំងអស់ដែលមានសម្រាប់យើងនៅពេលនេះ ទាំងនៅក្នុងទម្រង់ជាសេចក្តីព្រាង ឬទម្រង់ជាឯកសារកំពុងរៀបចំ។ ការវាយតម្លៃនេះមានប្រសិទ្ធភាពនៅពេលដែលមូលបត្របំណុលត្រូវបានបោះផ្សាយ ហើយឯកសារទាំងអស់ត្រូវបានអនុម័តដោយអាជ្ញាធរពាក់ព័ន្ធ។ ការវាយតម្លៃនឹងត្រូវបានព្យួរ ឬដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ឬលុបចោលប្រសិនបើមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ណាមួយពីកិច្ចសន្យាធានា។ ការវាយតម្លៃនេះអាស្រ័យទៅលើការកែសម្រួល "ប្រការ ២០" ដែលជាប្រយោគត្រឹមត្រូវជំនួសឱ្យ "ប្រការ ២០០" ក្រោមប្រការ ២០ ដំណោះស្រាយវិវាទនៅក្នុងកិច្ចព្រមព្រៀងធានាដែលបានចុះហត្ថលេខារួច។

យើងផ្តើមការវាយតម្លៃលទ្ធភាពសងរបស់ ស៊ីអាយអេ ហ្វីស អ៊ិនធើណេសិនណល ស្កូល ដោយការផ្តល់ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ (BCR) khAAA (ចំណាត់ថ្នាក់ជាតិ) ដែលនៅក្នុងបរិបទកម្ពុជាបង្ហាញនូវ «សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ»។ នៅក្នុងវិធីសាស្ត្ររបស់យើង BCR ត្រូវបានវិភាគដោយផ្អែកលើសមាសភាគពីរ ៖ ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន (ICR) និង ពិន្ទុស្តារឡើងវិញ (RS)។

ពិន្ទុស្តារឡើងវិញស្មើនឹង (RS) «ហានិភ័យទាបណាស់»។ មូលបត្របំណុលគឺត្រូវបានធានាសងដែលមិនអាចដកហូតវិញបាន និងដោយគ្មានលក្ខខណ្ឌចំពោះការខកខានទូទាត់ការប្រាក់ ឬប្រាក់ដើមជាមួយទំហំនៃការធានាសរុបគឺ ១០០% ទៅលើទាំងប្រាក់ដើម និងការប្រាក់ដោយក្រុមហ៊ុន CGIF ដែលជាស្ថាប័នទទួលបានចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន AA (សកល) ដោយ S&P និង AAA (ជាតិ) ដោយ RAM Ratings (ម៉ាឡេស៊ី) TRIS (ថៃ) Fitch Ratings Indonesia និង Pefindo CRA (ឥណ្ឌូនេស៊ី)។ អាស្រ័យហេតុនេះ យើងផ្តល់ចំណាត់ថ្នាក់នៃ khAAA លើមាត្រដ្ឋានជាតិរបស់យើង សម្រាប់ការវាយតម្លៃឥណទានសញ្ញាបណ្ណ។

តាមទស្សនៈរបស់យើង កិច្ចព្រមព្រៀងធានាបង្ហាញអំពីភាពត្រឹមត្រូវនៃការជំនួសឥណទានពី ICR នៃស៊ីអាយអេ ហ្វីស អ៊ិនធើណេសិនណល ស្កូល ដោយ ICR នៃ CGIF។ ក្នុងករណីមានការខកខានសងបំណុល ម្ចាស់បំណុលត្រូវបានការពារដោយការធានាដែលមិនអាចដកហូតវិញបាន និងដោយគ្មានលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់ទាន់ពេលវេលាដោយ CGIF។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៣

## ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ(បន្ត)

ការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនផ្សំដោយសមាសភាគពីរៈ ទម្រង់ឥណទានឯករាជ្យ (SACP) និងកត្តាគាំទ្រខាងក្រៅ (ESF)។ SACP វិភាគទម្រង់ឥណទានតាមរយៈហានិភ័យអាជីវកម្ម និងហានិភ័យហិរញ្ញវត្ថុរបស់ ស៊ីអាយអេ ហ្វឺស អ៊ិនធើណេសិនណល ស្គូល ។ ស៊ីអាយអេ ហ្វឺស អ៊ិនធើណេសិនណល ស្គូល «សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច»។ ការវាយតម្លៃ SACP ចំណាត់ថ្នាក់ khBB បង្ហាញពីទម្រង់ «ហានិភ័យមធ្យម» ។ យើងកត់សម្គាល់ទាំងការកើនឡើងនៃការចុះឈ្មោះពីការពង្រីកសាខាពីមុន និងផែនការពង្រីកបន្ថែមទៀតដែលនឹងបង្កើនការចំណាយថេរ និងកាត់បន្ថយប្រាក់ចំណេញនាពេលអនាគតនៅកំឡុងឆ្នាំដំបូងៗ។

## ការវាយតម្លៃ

ដោយសារប្រាក់ចំណូលពឹងផ្អែកជាចម្បងលើការផ្តល់សេវាអប់រំ វាមានស្ថិរភាពដោយសារតែចំណាយប្រភេទនេះជាចំណាយចាំបាច់សម្រាប់គ្រួសារនីមួយៗ។ ការពង្រីកសាខាដែលបានគ្រោងទុកនឹងបង្កើនតម្រូវការ CAPEX និងដាក់សម្ពាធបន្ថែមទៀតលើប្រាក់ចំណេញសុទ្ធ ជាពិសេសក្នុងអំឡុងពេលប៉ុន្មានឆ្នាំដំបូងៗ ដោយសារការកើនឡើងនៃការចុះឈ្មោះនៅមិនទាន់អាចទប់ទល់ការចំណាយបន្ថែមបាន។

តម្រូវការដើមទុនសម្រាប់ការពង្រីកសាខាក៏ត្រូវបានពិចារណាផងដែរ និងមានការប្រើប្រាស់ហិរញ្ញប្បទានជាមួយនឹងផ្នែកនៃការចេញសញ្ញាបណ្ណនេះ។ អាស្រ័យហេតុនេះ ចំណូលទំនងជានៅតែមានស្ថេរភាព ហើយកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើពិពិធកម្មប្រភពដើមទុនទំនងជានឹងនាំទៅរកការមានប្រសិទ្ធភាពថវិកាជាងមុន ប៉ុន្តែប្រាក់ចំណេញត្រូវបានរំពឹងថានឹងធ្លាក់ចុះជាពិសេសនៅឆ្នាំដំបូង។

## កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ដើម្បីពិចារណាលើការបង្កើនឡើងនូវចំណាត់ថ្នាក់ ICR របស់ក្រុមហ៊ុនអោយប្រសើរឡើង យើងត្រូវការតាមដាននិងពិនិត្យជាក់ស្តែង លើប្រាក់ចំណេញជាបន្តបន្ទាប់ និងការកាត់បន្ថយនូវទំហំបំណុលរបស់ ស៊ីអាយអេ ហ្វឺស អ៊ិនធើណេសិនណល ស្គូល។ ក្នុងករណីដែល ប្រាក់ចំណេញដែលមានការថយចុះ ការកើនឡើងនៃទំហំបំណុល និងការបែងចែកភាគលាភច្រើន អាចបណ្តាលឲ្យយើងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ ICR។

ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ យោងចំណាត់ថ្នាក់ជាសកលរបស់ CGIF (AA ដោយ S&P Global Ratings) ។ ដូច្នេះ យើងអាចពិចារណាលើការបន្ទាបចំណាត់ថ្នាក់ BCR ប្រសិនបើការវាយតម្លៃជាសកលរបស់ CGIF ត្រូវបានបន្ទាបចំណាត់ថ្នាក់។

## បញ្ហាដែលត្រូវត្រួតពិនិត្យ

ការទទួលបានអាជ្ញាប័ណ្ណសម្រាប់សាខាទីបួនពាក់ព័ន្ធទៅនឹងការបោះផ្សាយមូលបត្របំណុលនេះ ដោយសារប្រាក់ចំណូលពីការបោះផ្សាយមូលបត្របំណុលនេះគឺដើម្បីផ្តល់ហិរញ្ញប្បទានដល់ការសាងសង់សាខាថ្មី និងការវិនិយោគពាក់ព័ន្ធនៅទីនោះ។ នៅដំណាក់កាលនេះ CIA បានស្នើសុំអាជ្ញាប័ណ្ណសម្រាប់សាខាទីបួន ប៉ុន្តែនៅរង់ចាំការអនុម័តនៅឡើយ។ ដូច្នេះ ការទទួលអាជ្ញាប័ណ្ណសម្រាប់សាខាទីបួន គឺជាកម្មវត្ថុដែលត្រូវត្រួតពិនិត្យ និងតាមដាន។

បន្ថែមពីនេះការទទួលបានអាជ្ញាប័ណ្ណសម្រាប់សាខាទីបួន ការកើនឡើងនៃទំហំបំណុលរបស់CIA ផែនការពង្រីក ការចុះឈ្មោះ ការប្រើប្រាស់សមត្ថភាពចុះឈ្មោះអតិបរមាបច្ចុប្បន្ន និងផែនការចែកចាយភាគលាភ គឺជាចំណុចដ៏សំខាន់ដែលត្រូវត្រួតពិនិត្យ និងតាមដានផងដែរ។

## សេចក្តីសង្ខេបអំពី ស៊ីអាយអេ ហ្វឺស អ៊ិនធើណាសិនណល ស្គូល

## ទិដ្ឋភាពទូទៅ

ស៊ីអាយអេ ហ្វឺស អ៊ិនធើណេសិនណល ស្គូល (ហៅកាត់ថា "CIA") គឺជាសាលាឯកជនអន្តរជាតិមួយក្នុងប្រទេសកម្ពុជា ដែលផ្តល់កម្មវិធីអប់រំចាប់ពីថ្នាក់មត្តេយ្យដល់វិទ្យាល័យ។ CIA ត្រូវបានចុះបញ្ជីនៅក្នុងឆ្នាំ ២០១៦។ CIA ទទួលបានអាជ្ញាប័ណ្ណពីក្រសួងអប់រំ យុវជន និងកីឡា (MoEYS)។ បន្ថែមពីនេះ សាលានេះក៏ត្រូវបានទទួលស្គាល់ដោយ The Accrediting Commission for Schools, Western Association of Schools and Colleges (ACS WASC), Quality Matters, និង The Institute for Habits of Mind។ បច្ចុប្បន្ន CIA មានសាខាចំនួនបីៈ CIA FIRST សែនសុខ(K3-G8) វិទ្យាល័យ CIA FIRST សែនសុខ(G9-G12) និង CIA First ច្បារអំពៅ។ CIA គ្រោងនឹងបើកសាខាទីបួននៅខាងជើងរាជធានីភ្នំពេញ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៣

## ការប្រតិបត្តិ

CIA មានចំណេញក្នុងឆ្នាំវិជ្ជមានក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ បើទោះបីជាប្រាក់ចំណេញបានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ ២០២១ ដោយសារតែការបើកសាខាទីពីរ (CIA FIRST ច្បារអំពៅ) ក្នុងខែកញ្ញា ឆ្នាំ ២០២០ និងសាខាទីបី (វិទ្យាល័យ CIA FIRST សែនសុខ) នៅក្នុងខែកុម្ភៈ ឆ្នាំ ២០២១ ដែលបានបង្កើនការចំណាយរំលស់ និងចំណាយថេរផ្សេងទៀត ដើម្បីដំណើរការសាខាថ្មី។ ការកើនឡើងយ៉ាងខ្លាំងនៃចំណាយរំលស់នៅតែជះឥទ្ធិពលអវិជ្ជមានដល់ចំណេញសម្រាប់ឆ្នាំសារពើពន្ធ ២០២២ ដោយសារ កំណើនចំណូលពីកំណើននៃការចុះឈ្មោះនៅតែមិនអាចទូទាត់ការចំណាយទាំងនេះបាននៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ CIA អាចបង្កើនចំនួនចុះឈ្មោះចូលរៀននៅឆ្នាំសិក្សា ២០២៣ ដល់ទៅ ២៩%។ ដូច្នេះ យើងរំពឹងថា CIA នឹងមានចំណាយដើមទុនបន្ថែម (CAPEX) ដែលពាក់ព័ន្ធទៅនឹងការពង្រីកសាខាថ្មី និងការថែទាំសាខាដែលមានស្រាប់។

| | ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២២ | | ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| ទ្រព្យសកម្ម | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 51,349,394 | 12,502,896 | 22,461,526 | 5,505,276 |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | **55,162,105** | **13,431,241** | **25,167,952** | **6,168,616** |
| ទ្រព្យសម្បត្តិ និង គ្រឿងបរិក្ខារ | 139,352,789 | 33,930,555 | 144,873,432 | 35,508,194 |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | **179,655,904** | **43,743,828** | **187,120,305** | **45,862,820** |
| **ទ្រព្យសកម្មសរុប** | **234,818,009** | **57,175,069** | **212,288,257** | **52,031,436** |
| បំណុល | | | | |
| បំណុលភតិសន្យា | 231,939 | 56,474 | 193,343 | 47,388 |
| ប្រាក់កម្ចី | 7,273,719 | 1,771,054 | 11,029,607 | 2,703,335 |
| **បំណុលរយៈពេលខ្លីសរុប** | **60,910,233** | **14,830,833** | **39,786,350** | **9,751,556** |
| បំណុលភតិសន្យា | 43,396,386 | 10,566,444 | 43,166,752 | 10,580,087 |
| ប្រាក់កម្ចី | 29,118,441 | 7,089,954 | 31,507,784 | 7,722,496 |
| **បំណុលរយៈពេលវែងសរុប** | **72,853,406** | **17,738,838** | **74,988,634** | **18,379,568** |
| **បំណុលសរុប** | **133,763,639** | **32,569,671** | **114,774,984** | **28,131,124** |
| មូលធន | | | | |
| ដើមទុន | 5,256,960 | 1,280,000 | 5,222,400 | 1,280,000 |
| បុព្វលាភភាគហ៊ុន | 60,455,040 | 14,720,000 | 60,057,600 | 14,720,000 |
| ចំណេញរក្សាទុក | 34,893,088 | 8,605,398 | 32,023,387 | 7,900,312 |
| **មូលធនសរុប** | **101,054,370** | **24,605,398** | **97,513,273** | **23,900,312** |
| **បំណុលនិងមូលធនសរុប** | **234,818,009** | **57,175,069** | **212,288,257** | **52,031,436** |

| | ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២២ | | ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | | |
| សាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ | 40,344,258 | 9,912,594 | 16,931,453 | 4,163,131 |
| សាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន | (6,387,377) | (1,569,380) | 12,467,433 | 3,065,511 |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | (5,546,824) | (1,345,594) | (43,011,949) | (10,575,842) |
| **(តំហយ)/កំណើន សាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ** | **28,410,057** | **6,997,620** | **(13,613,063)** | **(3,347,200)** |

| | ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២២ | | ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **របាយការណ៍ចំណេញ/ខាត** | | | | |
| ចំណូល | 72,607,054 | 17,839,571 | 66,264,652 | 16,293,251 |
| ចំណេញប្រតិបត្តិការ | 9,694,952 | 2,382,052 | 7,400,943 | 1,819,755 |
| ចំណេញមុនពេលបង់ពន្ធលើប្រាក់ចំណូល | 2,869,700 | 705,086 | 979,337 | 240,801 |
| **ចំណេញ/(ខាត)ក្នុងឆ្នាំ** | **2,869,700** | **705,086** | **979,337** | **240,801** |

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៣

## និយមន័យចំណាត់ថ្នាក់ឥណទាន

| ចំណាត់ថ្នាក់វាយតម្លៃឥណទាន (ចំណាត់ថ្នាក់ជាតិ) | | | |
|---|---|---|---|
| **ចំណាត់ថ្នាក់ជាតិ** | **និយមន័យ** | | |
| khAAA | សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ១ | ហានិភ័យទាបណាស់ |
| khAA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ២ | |
| khA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៣ | ហានិភ័យទាប |
| khBBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៤ | |
| khBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៥ | ហានិភ័យមធ្យម |
| khB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៦ | |
| khCCC | សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល | ៧ | ហានិភ័យខ្ពស់ |
| khCC | សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៨ | |
| khC | ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៩ | ហានិភ័យខ្ពស់ណាស់ |
| khD | មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់ | ១០ | |

**សេចក្តីថ្លែងមិនទទួលខុសត្រូវ**

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៣

#២៤៦, មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
www.ratingagencyofcambodia.com.kh | (+៨៥៥)២៣ ៩០២ ៥០៨ | info@ratingagencyofcambodia.com.kh